ឧបសម្ព័ន្ធ ៣.១៦ : សេចក្តីប្រកាសផ្សព្វផ្សាយស្វែងរកអ្នកផ្តល់សេវាកម្ម

## សេចក្តីជូនដំណឹងស្តីពី
## ការស្វែងរកអ្នកផ្តល់សេវាកម្មសម្រាប់ការរៀបចំ និងអនុវត្តគម្រោងបង្កើនប្រាក់ចំណូល
## ក្រោមក្របខ័ណ្ឌនៃមូលនិធិទ្រទ្រង់ជីវភាពសហគមន៍

| ខេត្ត :សៀមរាប | ស្រុក :សូទ្រនិគម | ឃុំ :កំពង់ឃ្លាំង |
|---|---|---|

ប្រវត្តិសង្ខេប:

ក្នុងឆ្នាំ២០១០នេះ ក្រុមប្រឹក្សាឃុំ**កំពង់ឃ្លាំង**ទទួលបានការគាំទ្រមូលនិធិទ្រទ្រង់ជីវភាពសហគមន៍ ក្រោមក្របខ័ណ្ឌនៃគម្រោងទ្រទ្រង់ជីវភាពប្រជាជនបឹងទន្លេសាប តាមរយៈក្រសួងមហាផ្ទៃ សម្រាប់គាំទ្រលើការរៀបចំ និងអនុវត្តគម្រោងអាទិភាពនានា ដែលបានកំណត់នៅក្នុងកម្មវិធីវិនិយោគរបស់ឃុំ។ យោងតាមលទ្ធផលនៃការចាត់អាទិភាពគម្រោង និងយោងតាមល័ក្ខខ័ណ្ឌនៃការប្រើប្រាស់មូលនិធិទ្រទ្រង់ជីវភាពសហគមន៍ ក្រុមប្រឹក្សាឃុំបានសម្រេចជ្រើសរើសគម្រោងបង្កើតប្រាក់ចំណូលមួយចំនួន ដើម្បីធ្វើការរៀបចំ និងអនុវត្តនៅក្នុងឆ្នាំ២០១០នេះ។

ហេតុនេះ ដើម្បីរៀបចំ និងអនុវត្តគម្រោងបង្កើតប្រាក់ចំណូលទាំងនោះ ក្រុមប្រឹក្សាឃុំ**កំពង់ឃ្លាំង**សូមប្រកាសអញ្ជើញអ្នកផ្តល់សេវាកម្ម ដែលមានការចាប់អារម្មណ៍ ដើម្បីមករៀបចំសំណើគម្រោង និងអនុវត្តគម្រោងបង្កើតប្រាក់ចំណូល ដូចមានរៀបរាប់ខាងក្រោមនេះ:

| ល.រ | គម្រោង | ចំនួនគម្រោង | ចំនួនអ្នកទទួលផល ក្នុង១គម្រោង | ទីតាំងគម្រោង | តម្លៃអតិបរិមា ក្នុង១គម្រោង |
|---|---|---|---|---|---|
| *០១* | *ផលិតចំណីត្រី* | *០១* | *១០គ្រួសារ* | *ភូមិមុខវត្ត* | *១០.០០០ដុល្លារ* |
| | *សរុប* | *០១* | *១០គ្រួសារ* | | *១០.០០០ដុល្លារ* |

| | |
|---|---|
| រយៈពេលអនុវត្តគម្រោង: | *រហូតដល់នៃទី៣០ខែតុលាឆ្នាំ២០១០* |
| អ្នកដែលអាចមានសិទ្ធិចូលរួម: | *អង្គការមិនមែនរដ្ឋាភិបាល ឬភ្នាក់ងារផ្នែកឯកជន ដែលបានចុះបញ្ជីស្របច្បាប់ និងមានជំនាញ និងបទពិសោធន៍ពាក់ព័ន្ធនឹងការរៀបចំ និងអនុវត្តគម្រោងដូចខាងលើ។* |
| ទីកន្លែង និងពេលវេលា ដែលអាចទទួលឯកសារពាក់ព័ន្ធ: | *សាលាឃុំកំពង់ឃ្លាំងឬការិយាល័យក្រុមទ្រទ្រង់ជីវភាពសហគមន៍ ចាប់ពីថ្ងៃផ្សព្វផ្សាយព័ត៌មាននេះ នៅរាល់ម៉ោងធ្វើការ* |
| កាលបរិច្ឆេទទទួលសំណើគម្រោង: | *ថ្ងៃទី ១១ខែ ឧសភា ២០១០* |
| ទីកន្លែងទទួលសំណើគម្រោង | *សាលាឃុំ កំពង់ឃ្លាំង* |
| កាលបរិច្ឆេទវាយតម្លៃសំណើគម្រោង | *ថ្ងៃទី ១២ឧសភា ២០១០* |

កំណត់សម្គាល់ :

- ចំពោះសំណើគម្រោងនីមួយៗ គណៈកម្មការលទ្ធកម្មឃុំនឹងធ្វើការវាយតម្លៃលើសំណើគម្រោងផ្នែកបច្ចេកទេស និង សំណើតម្លៃបាន់ស្មានគម្រោងតាមរយៈការផ្តល់ពិន្ទុ។ គណៈកម្មការលទ្ធកម្មនឹងជ្រើសរើសយកសំណើគម្រោងណាដែលល្អជាងគេ មានន័យថា គឺជាគម្រោងដែលទទួលបានពិន្ទុសរុបខ្ពស់ជាងគេ ដើម្បីពិចារណាក្នុងការចុះកិច្ចសន្យាអនុវត្ត។
- ព័ត៌មានលម្អិតផ្សេងៗសូមទាក់ទងមក :
    - លោក ប៉ា ប៊ូរ ទូរស័ព្ទលេខ ០៧៧ ៥៦៤ ៣១១
    - លោក ភួង លីណា ទូរស័ព្ទលេខ ០១២ ៧៧៥ ៣៦៥

ថ្ងៃទី២៦ ខែ មេសា ឆ្នាំ២០១០

**មេឃុំ**

ប៉ា_ប៊ូរ